## ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

Inform-សជណ: 08-07-14 ម.ប.ល.P.74

អគ្គិសនីកម្ពុជា

លេខ : ៧២៧១ សជណ.ររក.រប

# សេចក្តីជូនដំណឹង

## ស្តីពី ការជ្រើសរើសបុគ្គលិក

អគ្គិសនីកម្ពុជាសូមជម្រាបជូនដំណឹងដល់សាធារណៈជនថា អគ្គិសនីកម្ពុជា ត្រូវការជ្រើសរើសបុគ្គលិក ចំនួន ១២ រូប ដើម្បីចូលបម្រើការងារ នៅអគ្គិសនីសៀមរាប នៃអគ្គិសនីកម្ពុជា ដូចខាងក្រោម:

*- **លក្ខណៈសម្បត្តិបេក្ខជន** :

១- បុគ្គលិកបេឡា ០១ រូប :

+បេក្ខជនភេទស្រី, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ

+បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%

+កម្រិតវប្បធម៌ : ចាប់ពី សញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ឡើងទៅ

+ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel

+ភាសាអង់គ្លេស : ចេះអាចប្រើការបាន ជាមធ្យម

+មានរូបសម្បត្តិ ស្រស់ស្អាត ។

២- បុគ្គលិកក្រុមលក់ថាមពល ០១ រូប :

+បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ

+បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%

+កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនីឡើងទៅ

+ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel

+ភាសាអង់គ្លេស : ចេះអាចប្រើការបាន ជាមធ្យម ។

៣- បុគ្គលិកវេនប្រចាំការចែកចាយ, ភ្នាក់ងារជួសជុលថែទាំបណ្តាញ LV, ភ្នាក់ងារជួសជុលថែទាំបណ្តាញ MV, និង ភ្នាក់ងារអន្តរាគមន៍ជួសជុល សរុប ០៩ រូប :

+បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ

+បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.III.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%

+កម្រិតជំនាញ : ចាប់ពីសញ្ញាប័ត្រមធ្យមបច្ចេកទេសអគ្គិសនីឡើងទៅ

+ចំណេះដឹងកុំព្យូទ័រ : ចេះ Microsoft Word-Excel

+ភាសាអង់គ្លេស : ចេះអាចប្រើការបាន ជាមធ្យម ។

៤- ភ្នាក់ងារសិក្សាប្លង់ ០១ រូប :

+បេក្ខជនទាំង ០២ ភេទ, មានអាយុចាប់ពី ១៨ ឆ្នាំ ដល់ ៣៥ ឆ្នាំ

+បៀវត្សរ៍ផ្តល់ជូន : បៀវត្សរ៍សុទ្ធ E.I.1 ក្នុងពេលសាកល្បងការងារ ០៣ ខែ ទទួលបាន 90%

+កម្រិតជំនាញ : ចាប់ពី សញ្ញាប័ត្រវិស្វករអគ្គិសនី ឡើងទៅ

+ចំណេះដឹងកុំព្យូទ័រ : AutoCad

+ភាសាអង់គ្លេស : ចេះអាចប្រើការបាន ជាមធ្យម ។

*- **បញ្ជាក់** : បេក្ខនារីគ្រប់ខេត្ត-ក្រុង និងបេក្ខជន ដែលមានអាសយដ្ឋានស្ថិតនៅខេត្តសាមី ប្រសិនបើលទ្ធផលពិន្ទុប្រហាក់ប្រហែលគ្នា គឺត្រូវផ្តល់អាទិភាព។

*- **បេក្ខជនត្រូវមកដាក់ពាក្យ និង ភ្ជាប់មកជាមួយនូវ** :

| | |
|---|---|
| - ពាក្យសុំចូលបម្រើការងារ មានបិទតែមប្រ៊ី( ១.០០០ រៀល ) | ចំនួន ០១ ច្បាប់ |
| - ប្រវត្តិរូបសង្ខេប មានបិទរូបថត ៤ x ៦ | ចំនួន ០១ ច្បាប់ |
| - សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ឬអាចយក សៀវភៅគ្រួសារឬអត្តសញ្ញាណប័ណ្ណ( ច្បាប់ចម្លងមានបញ្ជាក់ពី សាលារាជធានីភ្នំពេញ ឬសាលាខេត្ត )ឬលិខិតបញ្ជាក់ទីលំនៅ ចុះហត្ថលេខាពីខណ្ឌ-ស្រុក | ចំនួន ០១ ច្បាប់ |
| - លិខិតបញ្ជាក់កិរិយាមារយាទ | ចំនួន ០១ ច្បាប់ |
| - លិខិតបញ្ជាក់សុខភាព(ចេញដោយនាយកដ្ឋានពេទ្យការងារ នៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ) | ចំនួន ០១ ច្បាប់ |
| - ច្បាប់ចម្លងសញ្ញាប័ត្រចំណេះដឹងទូទៅ និងសញ្ញាប័ត្រជំនាញ មានបញ្ជាក់ពីសាលារាជធានីភ្នំពេញ ឬសាលាខេត្ត | ចំនួន ០១ ច្បាប់ |
| - តារាងពិន្ទុ ( TRANSCRIPT ) | ចំនួន ០១ ច្បាប់ |
| - លិខិតបញ្ជាក់ ឬ ច្បាប់ចម្លងសញ្ញាប័ត្រផ្សេងៗ (បើមាន) | ចំនួន ០១ ច្បាប់ |
| - លិខិតបញ្ជាក់ពីបទពិសោធន៍ការងារ (បើមាន) | ចំនួន ០១ ច្បាប់ |

*- **ទីកន្លែងទទួលពាក្យ** : សាលប្រជុំអគារ C ជាន់ទី៣ នៃអគ្គិសនីកម្ពុជា
ចាប់ពីថ្ងៃផ្សាយដំណឹងនេះ រហូតដល់ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤ រៀងរាល់ថ្ងៃធ្វើការ

- ពេលព្រឹក ចាប់ពីម៉ោង ០៨ : ០០ ដល់ម៉ោង ១១ : ៣០
- ពេលល្ងាច ចាប់ពីម៉ោង ១៤ : ០០ ដល់ម៉ោង ១៧ : ០០
- ពាក្យសុំចូលបម្រើការងារ ត្រូវប្រើប្រាស់គំរូ មានបោះត្រាសម្គាល់របស់អគ្គិសនីកម្ពុជា។

*- **ព័ត៌មានផ្សេងៗ** : សូមអញ្ជើញមកទាក់ទង ការិយាល័យរដ្ឋបាល នៃទីស្នាក់ការកណ្តាល អគ្គិសនីកម្ពុជា ឬតាមរយៈលេខទូរស័ព្ទ ០២៣ ៧២៣ ៩៧១ និង ០២៣ ៧២៤ ៧៧១។

រាជធានីភ្នំពេញ,ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១៤

ជ.ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា
ទទួលបន្ទុកជា អគ្គនាយកអគ្គិសនីកម្ពុជា
អគ្គនាយករង

ELECTRICITE DU CAMBODGE

អេង_គន្ធា